ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១១៥/១៣-ហារតា ផាកខេជីង អ៊ិនដាសស្ត្រី (ខេមបូឌា)

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហារតា ផាកខេជីង អ៊ីនដាសស្ត្រី (ខេមបូឌា) អិលធីឌី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៨ ៨៨៨ ៩២២៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកលើកទី១ ៖

| | |
|---|---|
| ១- លោក សូ ភក្តី | ប្រធានផ្នែករដ្ឋបាល |
| ២- កញ្ញា សុខនី | រដ្ឋបាល និង គណនេយ្យ |
| ៣- កញ្ញា អ៊ូវ អេឡែន | មេធាវី |

តំណាងភាគីនិយោជកលើកទី២ ៖

| | |
|---|---|
| ១- លោក សូ ភក្តី | ប្រធានផ្នែករដ្ឋបាល |
| ២- លោក ស៊ុំ ចំរ៉ុង | បុគ្គលិក |
| ៣- កញ្ញា អ៊ូវ អេឡែន | មេធាវី |



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖- **សហព័ន្ធសហជីពជាតិកម្មករកម្ពុជា**

អាសយដ្ឋាន ៖ ផ្ទះ ១៨ MG ផ្លូវ៤ AK សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៨៥៥ ៥៣៦ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតលើកទី១ ៖

| | |
|---|---|
| ១- លោក តុល ផាន់មឿង | ប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា |
| ២- លោក សុខ សុភាព | មន្ត្រីសហព័ន្ធសហជីពជាតិកម្មករកម្ពុជា |
| ៣- លោក ហែម សុខពន្លក | មន្ត្រីសភាសម្ព័ន្ធសហជីពជាតិកម្ពុជា |
| ៤- លោក ឈួន ដារុន | ប្រធានសហជីព |
| ៥- លោម អ៊ុំ សុភា | ប្រធានសហជីព |
| ៦- លោក ឆើត ឈឿន | លេខាសហជីព |
| ៧- លោក សេន ថុនា | ទីប្រឹក្សាសហជីព |
| ៨- លោក ផ្លួយ ហ៊ីន | ទីប្រឹក្សាសហជីព |
| ៩- លោក កន សារង្ស | ទីប្រឹក្សាសហជីព |
| ១០- លោក ធឿន ចាន់ថន | ទីប្រឹក្សាសហជីព |
| ១១- លោក អឿន ចាន់សុភ័ក្ត្រ | សកម្មជនសហជីព |
| ១២- លោក ឡុច លី | សកម្មជនសហជីព |
| ១៣- លោក សុន ម៉ារ៉ា | សកម្មជនសហជីព |
| ១៤- លោក ហួន វាសនា | សកម្មជនសហជីព |
| ១៥- លោក អ៊ី សុវី | សកម្មជនសហជីព |
| ១៦- លោក ម៉ី សុភក្ត្រា | សកម្មជនសហជីព |
| ១៧- លោក មាន បាត | អនុប្រធានទី២សហជីព |
| ១៨- លោក សាន ប៊ុនសាយ | សកម្មជនសហជីព |
| ១៩- លោក ហុក សន | សកម្មជនសហជីព |
| ២០- លោក ជីម វណ្ណា | សកម្មជនសហជីព |
| ២១- លោក ជាតិ លីដា | សកម្មជនសហជីព |
| ២២- កញ្ញា រ័ត្ន ចាន់ត្រីស្នា | សកម្មជនសហជីព |
| ២៣- កញ្ញា ជិន ចាន់ទី | សកម្មជនសហជីព |

THE ARBITRATION COUNCIL

២៤- កញ្ញា ណាល់ គីមស្រ៊ី សកម្មជនសហជីព

២៥- កញ្ញា ខឹម សោភាស់ សកម្មជនសហជីព

តំណាងភាគីកម្មករនិយោជិតលើកទី២ ៖

១- លោក តុល ផាន់មឿង ប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា

២- លោក សុខ ភាព មន្ត្រីសហព័ន្ធសហជីពជាតិកម្មករកម្ពុជា

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

ភាគីកម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនផ្តាច់កិច្ចសន្យាការងារ ដោយត្រូវទូទាត់ប្រាក់បំណាច់ផ្សេងៗ តាមច្បាប់ស្តីពីការងារ ដោយភាគីកម្មករនិយោជិតបានលើកហេតុផលថា ក្រុមហ៊ុនធ្វើការផ្លាស់ប្តូរថៅកែ និងមានការផ្លាស់ប្តូរអាវ ឬផ្លាកសញ្ញាពី HP ទៅ OSI ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការស្នើសុំរបស់ភាគីកម្មករនិយោជិតឡើយ ដោយភាគីក្រុមហ៊ុនអះអាងថា មិនមានការផ្លាស់ប្តូរថៅកែ ឬផ្លាស់ប្តូរឈ្មោះក្រុមហ៊ុនទេ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួមដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៦៦៦ កប/អក/វក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ** ៖

- ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក) ។
- ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងតាមទូរស័ព្ទតាមរយៈ តំណាងក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាស្រ្ទី (ខេមបូឌា) លីមីធីត អំពីករណីកម្មករនិយោជិត នៃក្រុមហ៊ុននេះ ធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនអនុវត្តនូវលក្ខខណ្ឌការងារចំនួន ០២ ចំណុច។ កូដកម្មនេះ ដឹកនាំដោយសហព័ន្ធសហជីពជាតិកម្មករកម្ពុជា។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សានៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ ដោយទទួលលទ្ធផលមិនសះជានឹងគ្នាចំនួន ១ ចំណុច លើការទាមទារចំនួន ០២ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៦៦៦ ក.ប/អក/វក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីទាំងពីរមកសវនាការលើកទី១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក និងសវនាការលើកទី២ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល។ តាមរយៈលិខិតចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ (ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលដោយភាគីកម្មករនិយោជិតនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣) កម្មករនិយោជិតចំនួន ១២ នាក់ នៃក្រុមហ៊ុន ហារតា ផាកខេជីង បានធ្វើការពឹងពាក់សហព័ន្ធសហជីពជាតិកម្មករកម្ពុជាឱ្យជួយដោះស្រាយលក្ខខណ្ឌការងារមួយចំនួននៅក្រុមហ៊ុន ហារតា ផាកខេជីង។ នៅថ្ងៃសវនាការលើកទី១ ភាគីនិយោជកមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ រីឯ ខាងភាគីកម្មករនិយោជិត ក៏មានការចូលរួមដោយកម្មករនិយោជិតដែលទាមទារ និងតំណាងសហព័ន្ធសហជីពជាតិកម្មករកម្ពុជាផងដែរ។ នៅថ្ងៃសវនាការលើកទី១នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទុកពេលឱ្យភាគីទាំងពីរត្រឡប់ទៅធ្វើការចរចាលើចំណុចវិវាទនេះ ដោយត្រូវជូនដំណឹងអំពីលទ្ធផលនៃការចរចាមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣។ មកដល់ថ្ងៃកំណត់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលការជូនដំណឹងអំពីលទ្ធផលនៃការចរចាដែលយកជាការបានពីភាគីទាំងពីរឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅភាគីទាំងពីរមកសវនាការលើកទី២ ដើម្បីសាកសួររកអង្គហេតុ និងធ្វើការពិចារណា សម្រេចសេចក្តីលើសំណុំរឿងនេះ។ នៅថ្ងៃសវនាការលើកទី២ ភាគីនិយោជកមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ រីឯ ខាងភាគីកម្មករនិយោជិត គឺមានតែតំណាងសហព័ន្ធសហជីពជាតិកម្មករកម្ពុជាប៉ុណ្ណោះ ដែលចូលរួមសវនាការលើកទី២ នេះ។ នៅថ្ងៃសវនាការលើកទី២ នេះ ភាគីនិយោជកបានបញ្ជាក់ថា និយោជកបានចរចាព្រមព្រៀងដោះស្រាយចំណុចវិវាទនេះ ជាមួយកម្មករនិយោជិតដែលទាមទាររួចរាល់ហើយ ហើយកម្មករនិយោជិតទាំងនោះក៏បានលាលែងពីការងារដែរ។ តំណាងសហព័ន្ធសហជីពជាតិកម្មករកម្ពុជា បានបញ្ជាក់ថា សហព័ន្ធមិនជំទាស់នឹងការលើកឡើងរបស់ភាគីនិយោជកនេះទេ ពីព្រោះ សហព័ន្ធមិនពាក់ព័ន្ធនឹងការព្រមព្រៀងនេះទេ។ ដូចនេះ សហព័ន្ធមិន

ទទួលខុសត្រូវចំពោះការព្រមព្រៀងនេះទេ។ លើសពីនេះ តំណាងសហព័ន្ធបានបញ្ជាក់ថា សហព័ន្ធមកចូលរួមសវនាការលើកទី២ នេះ គឺដើម្បីបញ្ជាក់ប្រាប់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលថា សហ័ពន្ធមិនមានការទទួលពឹងពាក់ពីកម្មករនិយោជិតដែលទាមទារទៀតទេ ពីព្រោះ កម្មករនិយោជិតដែលបានពឹងពាក់សហព័ន្ធនោះ លែងបម្រើការងារនៅក្រុមហ៊ុនទៀតហើយ។

ភាគីទាំងពីរបានឯកភាពពន្យារថ្ងៃចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ទៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាលើចំណុចវិវាទខាងលើនេះ ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ របស់នាយកក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្ទ្រី ប្រគល់សិទ្ធិជូន មេធាវី ហំ ភា និងមេធាវី អ៊ូរ អេឡែន ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣។

២- លិខិតបញ្ជាក់របស់កម្មករចំនួន ២៦ នាក់ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីបញ្ជាក់លើ logo, ទង់ជាតិ និង អាវ របស់ក្រុមហ៊ុន ហារតា។

៣- សារណាសំណុំរឿងលេខ ១១៥/១៣ លេខ ០៦១ កហភ/១៣ របស់មេធាវី អ៊ូរ អេឡែន ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣។

៤- លិខិតពឹងពាក់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ របស់កម្មករ កម្មការិនី គោរពជូន លោក គុល ផាន់មឿង ប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា សំណើសុំជួយដោះស្រាយលក្ខខណ្ឌការងារមួយចំនួន។

៥- កំណត់ហេតុប្រជុំផ្សះផ្សា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការពិនិត្យសម្របសម្រួល និងដោះស្រាយករណីកម្មករនិយោជិតក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្ទ្រី (ខេមបូឌា) លីមីតធីត។

៦- លិខិតលេខ ៣៤៦៦ ពណ.ចបព ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជម្រាបមក លោក CHAN CHOR NGIAK ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្ទ្រី (ខេមបូឌា) លីមីធីត ស្ដីពីការសុំកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន។

៧- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ៧០៤៤ ពណ.ចបព របស់ក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្ទ្រី (ខេមបូឌា) លីមីធីត ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១។

THE ARBITRATION COUNCIL

៨- ប័ណ្ណប៉ាតង់ឆ្នាំ២០១៣ លេខ DLT 039780.2013 ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្រ្ទី (ខេមបូឌា) លីមីធីត។

៩- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្រ្ទី (ខេមបូឌា) លីមីធីត ចុះបញ្ជិកាលេខ ៧៧ កប/អក/វក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩។

១០- លក្ខន្តិកៈក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាសស្រ្ទី (ខេមបូឌា) លីមីធីត តំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម លេខ ៤១៩/០៤ ពណ.ចបព ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ ២០១២។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហារតា លេខ ៦៦៦ កប/អក/វក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហារតា ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៥៩០ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៥៩១ កប/អក/វក/លកអ. ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៦៦៩ កប/អក/វក/លកអ. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៦៧០ កប/អក/វក/លកអ. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារ

កម្មករនិយោជិតដែលទាមទារផ្ទាល់មិនបានចូលរួមសវនាការលើកទី២ ហើយបានធ្វើការចរចាព្រមព្រៀងដោះស្រាយចំណុចវិវាទនេះជាមួយនិយោជករួចរាល់ហើយ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម ៖

កថាខ័ណ្ឌទី១ នៃមាត្រា ៣១២ នៃច្បាប់ស្តីពីការងារ ចែងថា ៖ "*ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកនៃការវិវាទនោះទេប៉ុណ្ណោះ។*"

យោងតាមខ្លឹមសារនៃមាត្រាខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភារកិច្ចដោះស្រាយ និងសម្រេចសេចក្តីលើចំណុចវិវាទមិនសះជា ដែលមានបញ្ជាក់នៅក្នុងកំណត់ហេតុមិនសះជាដែលបញ្ជូនដោយរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ និងបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកនៃការវិវាទនោះតែប៉ុណ្ណោះ ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជកបានបញ្ជាក់ថា និយោជកបានចរចាព្រមព្រៀងដោះស្រាយចំណុចវិវាទនេះជាមួយកម្មករនិយោជិតដែលទាមទាររួចរាល់ហើយ ហើយកម្មករនិយោជិតទាំងនោះ ក៏បានលាលែងពីការងារដែរ ។ តំណាងសហព័ន្ធសហជីពជាតិកម្មករកម្ពុជាបានបញ្ជាក់ថា សហព័ន្ធមិនជំទាស់នឹងការលើកឡើងរបស់ភាគីនិយោជកនេះទេ ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជក និងកម្មករនិយោជិតដែលធ្វើការទាមទារមានការព្រមព្រៀងដោះស្រាយចំណុចវិវាទនេះរួចរាល់ហើយ ។ លើសពីនេះ កម្មករនិយោជិតដែលធ្វើការទាមទារមិនមានវត្តមាននៅក្នុងសវនាការលើកទី២ ទេ ។

នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទមិនសះជានៅក្នុងសំណុំរឿងនេះដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហារតា ផាកខេជីង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ លេខ ៦៦៦ ក.ប./អក/វក ត្រូវបានដោះស្រាយតាមរយៈការព្រមព្រៀងរវាងភាគីវិវាទរួចរាល់ហើយ ។ ដូចនេះ សំណុំរឿងនេះ មិនមានចំណុចវិវាទមិនសះជាសម្រាប់ឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាសម្រេចសេចក្តីទៀតទេ ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ១១៥/១៣-ហារតា ផាកខេជីង អ៊ិនដាសស្ទ្រី នេះ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

**សម្រេច និង បង្គាប់**

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ **១១៥/១៣-ហារតា ផាកខេជីង អ៊ិនដាសស្ទ្រី** ។

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា ៖ ----------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL